ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន
លេខ: ១៧២ ប្រ.ក.ប.ស្ថ

# ប្រកាស
## ស្តីពី
## ការទទួលស្គាល់សហគមន៍តំបន់ការពារធម្មជាតិ «កំពង់ដំរី» នៃរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ ស្ថិតនៅភូមិកំពង់ដំរី ឃុំបឹងចារ ស្រុកសំបូរ ខេត្តក្រចេះ

## រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការគ្រប់គ្រងតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាល ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការបង្កើតដែនជម្រកសត្វព្រៃ«ព្រៃឡង់»
- បានឃើញអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ ស្តីពីការបង្កើតរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងបរិស្ថាន

## សម្រេច

**ប្រការ១.-**

ត្រូវបានទទួលស្គាល់សហគមន៍តំបន់ការពារធម្មជាតិ **«កំពង់ដំរី»** នៃរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ ស្ថិតនៅភូមិកំពង់ដំរី ឃុំបឹងចារ ស្រុកសំបូរ ខេត្តក្រចេះ។

**ប្រការ២._**

សហគមន៍តំបន់ការពារធម្មជាតិ **«កំពង់ដំរី»** នៃរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ មានផ្ទៃដីសរុបទំហំ ១៣០២ហិកតា (មួយពាន់បីរយពីរហិកតា) ដូចមានផែនទីភ្ជាប់ជាឧបសម្ព័ន្ធ កំណត់ដោយចំណុចគោល ដែលមាននិយាមកា (Datum: WGS1984) ដូចក្នុងតារាងខាងក្រោម៖

| ID | X | Y |
|---|---|---|
| A | 602985 | 1445391 |
| B | 603204 | 1445219 |
| C | 603450 | 1445292 |
| D | 603664 | 1445359 |
| E | 603982 | 1445238 |
| F | 604225 | 1445026 |
| G | 605058 | 1444805 |
| H | 604355 | 1443760 |
| I | 603453 | 1443398 |
| J | 603277 | 1443398 |
| K | 603277 | 1442943 |
| L | 603429 | 1442710 |
| M | 603651 | 1442527 |
| N | 603447 | 1442229 |
| 0 | 603438 | 1441883 |
| P | 603465 | 1441520 |
| Q | 603313 | 1441239 |
| R | 603290 | 1440940 |
| S | 603441 | 1440735 |
| T | 600835 | 1440821 |
| U | 600812 | 1441273 |
| V | 600938 | 1441986 |
| W | 601025 | 1442286 |
| X | 600776 | 1442834 |
| Y | 601053 | 1443315 |
| Z | 601168 | 1445287 |

**ប្រការ៣._**

ការរៀបចំបង្កើតសហគមន៍តំបន់ការពារធម្មជាតិ **«កំពង់ដំរី»** ក្នុងគោលបំណងបង្កើនការចូលរួមគ្រប់គ្រងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព និងរួមចំណែកលើកកម្ពស់ជីវភាពសហគមន៍មូលដ្ឋានស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

**ប្រការ៤._**

សហគមន៍តំបន់ការពារធម្មជាតិ **«កំពង់ដំរី»** នៃរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ ត្រូវចុះកិច្ចព្រមព្រៀងជាមួយអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន នៃក្រសួងបរិស្ថាន ។ សហគមន៍តំបន់ការពារធម្មជាតិ **«កំពង់ដំរី»** ត្រូវរៀបចំលក្ខន្តិកៈ និងផែនការគ្រប់គ្រងស្របតាមច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ។

**ប្រការ៥._**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦._**

នាយកខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព គ្រប់អគ្គនាយក នៃអគ្គនាយកដ្ឋានចំណុះក្រសួង អគ្គាធិការ នៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរបរិស្ថានខេត្តក្រចេះ និងប្រធានសហគមន៍តំបន់ការពារធម្មជាតិ **«កំពង់ដំរី»** ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃ អង្គារ ១៣ រោច ខែ ផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ មេសា ឆ្នាំ២០១៩

**រដ្ឋមន្ត្រី**

**សាយ សំអាល់**

**<u>កន្លែងទទួល</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលខេត្តក្រចេះ
- ដូចប្រការ៦ «ដើម្បីអនុវត្ត»
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ផែនទី ព្រំប្រទល់សហគមន៍តំបន់ការពារធម្មជាតិ "កំពង់ដី" ក្នុងរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ

## ភូមិសាស្ត្រភូមិកំពង់ដី ឃុំបឹងចារ ស្រុកសំបូរ ខេត្តក្រចេះ ទំហំ១៣០២ហិកតា

ឧបសម្ព័ន្ធ : ប្រកាសលេខ......១៥៤......ចុះថ្ងៃទី០៤ ខែ...... ឆ្នាំ២០១៩ របស់ក្រសួងបរិស្ថាន




និយាមកាព្រំប្រទល់សហគមន៍
តំបន់ការពារធម្មជាតិ កំពង់ដី

| ID | Coor_X | Coor_Y |
|---|---|---|
| A | 602985 | 1445391 |
| B | 603204 | 1445219 |
| C | 603450 | 1445292 |
| D | 603664 | 1445359 |
| E | 603982 | 1445238 |
| F | 604225 | 1445026 |
| G | 605058 | 1444805 |
| H | 604355 | 1443760 |
| I | 603453 | 1443398 |
| J | 603277 | 1443398 |
| K | 603277 | 1442943 |
| L | 603429 | 1442710 |
| M | 603651 | 1442527 |
| N | 603447 | 1442229 |
| O | 603438 | 1441883 |
| P | 603465 | 1441520 |
| Q | 603313 | 1441239 |
| R | 603290 | 1440940 |
| S | 603441 | 1440735 |
| T | 600835 | 1440821 |
| U | 600812 | 1441273 |
| V | 600938 | 1441986 |
| W | 601025 | 1442286 |
| X | 600776 | 1442834 |
| Y | 601053 | 1443315 |
| Z | 601168 | 1445287 |